**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥.១៤...០២០...០០៧...ប្រ.ភ.ព.ម

ថ្ងៃពុធ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ តុលា ឆ្នាំ ២០២០

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## ការដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគង

នៅថ្ងៃពុធ ១២កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជារៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធបាគង។ ការអភិវឌ្ឍន៍ប្រព័ន្ធបាគងជាគំនិតផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជាក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់សងប្រាក់នៅក្នុងប្រទេសកម្ពុជា ឆ្លើយតបទៅនឹងការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន។

ប្រព័ន្ធបាគងជាប្រព័ន្ធទូទាត់ឆ្អឹងខ្នងមួយដែលជួយសម្រួលការផ្ទេរប្រាក់និងទូទាត់សងប្រាក់ឆ្លងគ្រឹះស្ថាន (Interoperability) ជាអេឡិចត្រូនិក ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។ តាមរយៈប្រព័ន្ធបាគង អតិថិជនអាចធ្វើប្រតិបត្តិការពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ (P2P) ជាអេឡិចត្រូនិកភ្លាមៗ ដូចជា ការទូទាត់ ផ្ទេរប្រាក់ ដាក់ប្រាក់ និងដកប្រាក់ កាន់តែមានភាពងាយស្រួល ឆាប់រហ័ស កាត់បន្ថយចំណាយថ្លៃប្រតិបត្តិការ និងមានសុវត្ថិភាពខ្ពស់។

គិតចាប់ពីពេលដាក់ឱ្យដំណើរការសាកល្បងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ រហូតមកដល់ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ដែលជាថ្ងៃដាក់ឱ្យដំណើរការផ្លូវការនេះ មានគ្រឹះស្ថានសមាជិកចូលរួមដាក់ឱ្យដំណើរការប្រព័ន្ធបាគងចំនួន១៨គ្រឹះស្ថាន និងមានគ្រឹះស្ថានជាច្រើនទៀតបានទទួលការអនុញ្ញាតជាគោលការណ៍ឱ្យចូលជាសមាជិកប្រព័ន្ធបាគង និង កំពុងរៀបចំសិក្សាលក្ខណៈបច្ចេកទេសសម្រាប់តភ្ជាប់ប្រព័ន្ធ។

ប្រព័ន្ធបាគងនឹងរួមចំណែកក្នុងការជំរុញការទូទាត់មិនប្រើសាច់ប្រាក់ និងបរិយាប័ន្នហិរញ្ញវត្ថុក្នុងប្រទេស សំដៅអភិវឌ្ឍសេដ្ឋកិច្ចឆ្ពោះទៅរកសេដ្ឋកិច្ចផ្នែកឌីជីថលស្របតាមបដិវត្តឧស្សាហកម្មទី៤ និងបរិបទសេដ្ឋកិច្ចឌីជីថលក្នុងតំបន់។ មិនតែប៉ុណ្ណោះ ស្ថិតក្នុងបរិបទប្រទេសកំពុងទទួលរងវិបត្តិកូវីដ១៩ ដែលតម្រូវការទូទាត់អេឡិចត្រូនិកកំពុងមានការកើនឡើង ការដាក់ឱ្យដំណើរការផ្លូវការប្រព័ន្ធបាគងនៅថ្ងៃនេះ នឹងជួយគាំពារដល់សុខមាលភាពសង្គម និងទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ផងដែរ ជាពិសេសរួមចំណែកស្រោចស្រង់សេដ្ឋកិច្ចឡើងវិញតាមរយៈការសម្រួលការទូទាត់ជាអេឡិចត្រូនិកពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ដោយពុំប៉ះពាល់សាច់ប្រាក់ដោយផ្ទាល់។

ទំនាក់ទំនង៖
ផ្នែកទំនាក់ទំនងធនាគារជាតិនៃកម្ពុជា
លេខទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៩៦/ (៨៥៥) ៨៨ ៥៦៧០១៦៨